ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤០៤ ចុះថ្ងៃទី១៣
ខែកក្កដា ឆ្នាំ២០០៧
សាលក្រម
លេខ ៥០៤ (ខ) ចុះថ្ងៃទី
០៤ ខែកកដា ឆាំ២០២២

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពង់ចាម

-បានបើកសវនាការជាសាធារណៈ នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តកំពង់ចាម ដោយមានសមាសភាព ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៤ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុខខេង ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត[redacted] ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅភ[redacted] ខេត្តកំពង់ចាម, ប្រពន្ធឈ្មោះ[redacted]ស្រីវ័ត្ន មានកូនចំនួន០២នាក់ ,ឪពុកឈ្មោះ[redacted]ឈឹម (ស) ម្តាយឈ្មោះ[redacted]វ៉ាត(រ) រៀនថ្នាក់ទី៤ ជានីតិជន ទោសពីមុនគ្មាន ។

(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨២៣ ព្រ.ទ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២) ។

លោក [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted]សុខខេន ។

ជាប់ចោទពីបទ៖ ប្លន់ ប្រព្រឹត្តនៅភូមិទី១៥ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ឈឹម ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើនំប៉័ង មានទីកន្លែងកំណើតនៅភូមិត្រកួន ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅភូមិទី១០ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម, ប្រពន្ធឈ្មោះ [redacted]វ៉ាត មានកូនចំនួន០៥នាក់, មានឪពុកឈ្មោះ.....(រ-ស) ម្តាយឈ្មោះ.....(រ-ស) ជានីតិជន ទោសពីមុនគ្មាន ។

រឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ វេលាម៉ោង៥,៣០នាទី នៅចំណុចកែងមហោស្រពភូមិទី១៥ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ពិតជាមានអំពើស្នាក់ប្លន់យកម៉ូតូពីជនរងគ្រោះបង្កឡើងដោយក្រុមចោរ០៣នាក់ ក្នុងនោះមានឈ្មោះ [redacted] សុខខេង មានសាវតាជាតិគ្រប់គ្រាន់ តែ០២នាក់ទៀតគ្មានអត្តសញ្ញាណឡើយ ។

Scanned with CamScanner

បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ១៤២ ព.ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៥៨ ព.ស ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ។

បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៤៥៦ ចត ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកំពង់ចាម ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សុខខេង** បានឆ្លើយថា: ខ្លួនទទួលស្គាល់ការចោទប្រកាន់ កាលពីយកម៉ូតូម៉ាកសង់ការ៉េ ខ្លួនទៅនៅខាងប្រពន្ធនៅឧត្តុង ខ្លួនយកទៅលក់បានលុយចំនួន ៣០០$(បីរយដុល្លាអាមេរិក) យកលុយទៅដណ្តឹងប្រពន្ធរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃនេះ មានកូន០២នាក់ ខ្លួនពិតជាបានយកម៉ូតូឪពុកទៅលក់ពិតមែន ដោយសារខ្លួនអត់លុយចាយ តុលាការចោទប្រកាន់ពីបទ ប្លន់ នោះគឺមិនត្រឹមត្រូវទេ ម៉ូតូឪពុករបស់ខ្លួន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]រ៉ាត បានឆ្លើយថា: ខ្លួនជាប្រពន្ធរបស់ឈ្មោះ [redacted] ឈឹម ដែលបានទទួលមរណភាពនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ នៅពេលនេះខ្លួនមិនទាមទារសំណងអ្វីពីកូនឈ្មោះ [redacted] សុខខេង ទេ សុំឱ្យតុលាការមេត្តា ដោះលែងកូនរបស់ខ្លួនឈ្មោះ [redacted] សុខខេង ឱ្យមានសេរីភាពវិញផង ។

-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឈឹម** បានឆ្លើយថា: ខ្លួនសុំប្តឹងពីកូនប្រុសឈ្មោះ[redacted] សុខខេង ដែលបានស្នាក់ប្លន់ម៉ូតូពីកម្មករនំបុ័ងរបស់ខ្លួនកាលពីម៉ោង ៥,៣០នាទី ថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០០៧ នៅកែងមហោស្រពក្នុងភូមិទី១៥ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម។ កូនប្រុសខ្លួនឈ្មោះ [redacted] សុខខេង ក្រោយពីចេញពីគុកឆ្នាំ២០០៥ វាមិនដេកនៅផ្ទះទេ ហើយវាតែងតែបង្កបញ្ហារហូត ដូចជាគាស់ទូ គាស់ហិបយកលុយ នៅថ្ងៃមួយនោះវាបានចូលមកយកម៉ូតូនៅក្នុងផ្ទះ ទៅបញ្ចាំគេ រហូតដល់ខ្លួនទៅលោះយកមកវិញ អស់៣០០$ ហើយនៅកន្លះខែមុននេះ វាបានជួបម៉ែវានៅម្តុំផ្ទះតាហួ ក្រោយមេគង្គ ពេលនោះវាសុំម្តាយវា១០$ ម៉ែវាថាហ្អែងសុំអីក៏ងាយម្លេះ ពេលនោះវាបានបោះពាក្យសំដីឱ្យម្តាយវាថា បើម៉ែឯងមិនឱ្យម៉ែឯងនឹងស្តាយក្រោយហើយរហូតដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ កម្មកររបស់ខ្លួនឈ្មោះ[redacted] ធារ៉ា បានឌុបនំបុ័ងឱ្យគេនៅផ្សារបឹងកុក ត្រឡប់មកវិញនៅម៉ោង ៥,៣០នាទី មកដល់ម្តុំមហោស្រពកូនប្រុសខ្លួនឈ្មោះ [redacted] សុខខេង និងបក្សពួកវា០២នាក់ទៀតបានស្នាក់ប្លន់យកម៉ូតូរបស់ខ្លួនទៅបាត់។ ខ្លួនសូមបញ្ជាក់ថា ម៉ូតូរបស់ខ្លួនដែលកូនប្រុសខ្លួនឈ្មោះ [redacted] សុខខេង ប្លន់ពីកម្មករដឹកនំបុ័ង គឺម៉ាកសង់ការ៉េ ពណ៌កំបោរ លេខតួ ៩៩៨២០៦ លេខម៉ាស៊ីន ១៨៨៤០៧៦ ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] **ធារ៉ា ហៅ អាន** បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០០៧ ខ្លួនចេញពីផ្ទះទៅមើលគេលេងចាក់ក្តាមឃ្លោក នៅផ្ទះតាហួលក់កាហ្វេ ក្រោយមេគង្គ ម៉ោងប្រហែល៣ជាង នៅមើលគេលេងរហូតដល់ម៉ោងប្រហែល៩ជាង ខ្លួនបានចេញពីផ្ទះតាហួទៅលេងបៀនៅផ្ទះឌឿងហែម ក្នុងភូមិទី៩ ឃុំកំពង់ចាម (ផ្ទះជួលរបស់បងខេង) ពេលលេងមានគ្នា០៤នាក់មានឈ្មោះ បងហុង ឈ្មោះ បងខេង, ស្រីម្នាក់ខ្លួនមិនដែលស្គាល់ឈ្មោះ និងរូបខ្លួន លេងរហូតដល់ម៉ោងប្រហែលម៉ោង៥ទៀបភ្លឺ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៧ ពួកខ្លួនចាញ់អស់លុយមានរូបខ្លួន, បងហុង និងបងខេង ក៏ឈប់លេងបៀ បងហុងនាំសង្សារគាត់ទៅដេកផ្ទះជួល (ដៃចំណាន) ឯខ្លួនក៏ដើរមកដេកនៅផ្ទះខ្លួន រីឯបងខេងនិងខ្លួននៅអង្គុយជាមួយសង្សារគាត់នៅទីនោះ ខ្លួនមិនដឹងគាត់ទៅណាទេ ខ្លួនដេករហូតដល់ម៉ោងប្រហែល១០ជាង ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ ដដែល ម្តាយខ្លួនហៅខ្លួន ថាប៉ូលីសយកសំបុត្រហៅខ្លួន ទើបខ្លួនដឹងថាឈ្មោះបងខេងស្នាក់វាយយកម៉ូតូពីកម្មករនំបុ័ងរបស់គាត់។ ចំពោះរឿងស្នាក់វាយយកម៉ូតូពីកម្មករនំបុ័ងតាឈឹម ក្រោយមេគង្គ ខ្លួនពុំបានដឹងទេ ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សេងហុង បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០០៧ ខ្លួនបានទៅលេងបៀនៅផ្ទះជួលមួយនៅម្តុំខឿងហែម ម្ចាស់ផ្ទះនោះខ្លួនមិនស្គាល់ឈ្មោះទេ ពួកខ្លួន លេងចាប់ពីម៉ោង២រសៀល មានគ្នា០៤នាក់ មានខ្លួន, ម្ចាស់ផ្ទះ, អាខេង និងអាអាន ពួកខ្លួនលេងរហូតដល់ ម៉ោង៥ទៀបភ្លឺ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ ពួកខ្លួនឈប់លេងដោយសារខ្លួនអស់លុយ ពេលលេងអ្នកទាំង បួន ខ្លួនអ្នកចាញ់។ នៅពេលឈប់លេងខ្លួនបានចេញជាមួយសង្សារខ្លួនឈ្មោះ វី មកដេកនៅផ្ទះជួលម្តុំហាង គុយទាវតាគាត រីឯអាអាន និងអាខេង ខ្លួនមិនបានដឹងថាវាចេញស្មើណាទេ។ ខ្លួនសូមបញ្ជាក់ថាកន្លងមកអា ខេង ខ្លួនមិនបានដឹងថាវាមានពួកម៉ាកជាមួយអ្នកណាខ្លះទេ វាច្រើនតែដើរលេងម្នាក់វា ហើយកន្លងមកនេះតាម ខ្លួនដឹង អាខេងវាជំពាក់លុយគេច្រើនរឿងលេងល្បែង និងជំពាក់ថ្លៃជួល ហើយតាំងពីខ្លួនឮសូរថាវាស្នាក់វាយ យកម៉ូតូពីអ្នកឌុបនំប៉័ង ម៉ូតូឌីវាមក ខ្លួនមិនដែលឃើញវាទេ សង្សារវាឈ្មោះវ័ត្តក៏ទៅបាត់ដែរ ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] លីន បានឆ្លើយបញ្ជាក់ថា: ខ្លួន និងក្រុមគ្រួសារខ្លួនបានមកជួល ផ្ទះរបស់ឈ្មោះ មុនី នៅម្តុំផ្លូវខឿងហែមភូមិទី៩ ឃុំកំពង់ចាម ចំនួនមួយឆ្នាំហើយ។ នៅបន្ទប់ខ្លួនជួលនោះ មាន បន្ទប់តូចៗចំនួនពីរទៀត បន្ទប់មួយខ្លួនជួលឲ្យប៉ូលីសឈ្មោះ រឿន បន្ទប់មួយទៀតខ្លួនជួលឲ្យឈ្មោះ ខេង មាន ប្រពន្ធឈ្មោះ វ័ត្ត ប្រពន្ធលក់ស្រាបៀ និងឈ្មោះ ខេង មិនមានមុខរបរទេ ជាកូនរបស់ឈ្មោះ ឈីម ថៅកែឡ នំប័ុងក្រោយមេគង្គ។ កន្លងមកនៅផ្ទះខ្លួនជួលម្នាក់នៅនោះមិនដែលមានលេងល្បែងទេ ទើបតែនៅព្រឹកថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៧ ខ្លួនក៏បាននាំគ្នាលេងបៀក្រហម មានគ្នា០៤នាក់ មានខ្លួន អាខេង អាហុង ប្រពន្ធអា ហុង និងអាអាន ពួកខ្លួនលេងបៀពីម៉ោង៦ព្រឹក ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៧ រហូតដល់ម៉ោង៥ភ្លឺ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ ក៏នាំគ្នាឈប់ ពេលឈប់នោះអាខេងប្រពន្ធវា អាហុងប្រពន្ធវា និងអាអាន បាននាំគ្នាចេញ ពីផ្ទះជួលទៅបាត់ មិនដឹងជាវានាំគ្នាទៅណាទេ រហូតដល់ពេលនេះ។ ម៉ោង១៦ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ មិនទាន់ឃើញអាខេង និងប្រពន្ធវាចូលទៅបន្ទប់ជួលវិញឡើយ។ ខ្លួនសូមបញ្ជាក់ថា កន្លងទៅមិត្តភក្តិរបស់វា ដើរចូលទៅលេងជាមួយវាមានអាហុង និងអាអាន ក្រៅពីនេះមិនមានអ្នកណាទៀតទេ ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ឈឿន បានឆ្លើយបញ្ជាក់ថា: កាលពីម៉ោង៥:៣០នាទីថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៧ រៀងរាល់ព្រឹកខ្លួនត្រូវអ៊ុំឈីមម្ចាស់ឡនំប័ុង ប្រើឲ្យខ្លួនដឹកនំប័ុងឲ្យម៉ូយគ្រប់កន្លែង ហើយនៅព្រឹកថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ នេះ ខ្លួនឌុបនំប័ុងឲ្យម៉ូយដូចរៀងរាល់ព្រឹកដែរ ខ្លួនចេញឌុបនៅ ម៉ោង៥ ដំបូងខ្លួនយកទៅឲ្យម៉ូយនៅក្នុងផ្សារបឹងកុក លើកទី២ ខ្លួនឌុបឲ្យម៉ូយ នៅម្តុំកែងសាលាឧត្តរជ្រុងខាង លិចឈៀងខាងត្បូង រួចខ្លួនត្រឡប់មកវិញ មកដល់ម្តុំកែងមហោស្រពជ្រុងខាងកើតឈៀងខាងជើង ស្រាប់តែ ឈ្មោះ ខេងបានចេញមកស្គាក់ពីមុខម៉ូតូខ្លួន ខ្លួនក៏ឈប់ម៉ូតូ រួចឈ្មោះ ខេង បាននិយាយថាទុកម៉ូតូឲ្យអញ ខ្លួន ថាចាំទៅជួបអ៊ុំឈីមសិន ដោយមើលទៅមិនស្រួលខ្លួនប្រុងដកសោររត់ ភ្លាមនោះស្រាប់តែមានមនុស្សប្រុសពីរ នាក់មកវាយខ្លួនពីក្រោយចំនួនពីរដៃ ខ្លួនភ័យខ្លួនក៏រត់ចោលម៉ូតូតែម្តងទៅ ខ្លួនរត់បានប្រហែល៣០ម៉ែត្រ ពួក គេទាំងបីនាក់ ក៏បាននាំគ្នាជិះម៉ូតូនោះចេញទៅទិសខាងត្បូងបាត់ទៅ ដោយឈ្មោះ ខេង ជាអ្នកឌុប។ ខ្លួនសូម បញ្ជាក់ថាពីរនាក់ដែលលបវាយខ្លួនពីក្រោយ ខ្លួនមិនដែលស្គាល់ទេ ម្នាក់មានមាឌធំខ្ពស់អាយុខ្ចង់ជាងម្តែ ម្នាក់ ទៀតក៏មានមាឌមាំខ្មៅខ្ពស់អាយុខ្ចង់ជាងម្តែដែរ ។

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលរួចមកយើញថា ឈ្មោះ [redacted] សុខខេង ត្រូវចោទប្រកាន់ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិទី១៥ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ ជនជាប់ចោទចាប់ ខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើសួររួចហើយ ដោយជនជាប់ចោទវត្តមានចំពោះសវនាការបាន បញ្ជាក់ថា គាត់បានយកម៉ូតូ០១គ្រឿង ម៉ាកសង់ការ៉េពិតមែន អ្នកដែលជាដើមបណ្តឹងឈ្មោះ [redacted] ឈីម ត្រូវជា ឪពុក និងកូន នៅក្នុងអង្គហេតុនេះជាបទ ប្លន់ ប៉ុន្តែតាមមាត្រា ៣៥៥ ការប្រព្រឹត្តបទល្មើសមិនត្រូវចោទប្រកាន់ទេ ហេតុដូច្នេះតំណាងអយ្យការនៅតែក្បាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ១៤២ ព.ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ទុកជាបានការដដែល ប្តឹងសុំឲ្យតុលាការផ្តន្ទាទោសតាមច្បាប់ ។

មេធាវីការពារឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលរួចមក កូនក្តីខ្លួនឈ្មោះ [redacted] សុខខេង ដែលបានឆ្លើយនៅចំពោះមុខអង្គសវនាការនេះឃើញថា រឿងក្តីនេះគឺមានបណ្តឹងរបស់ឈ្មោះ [redacted] ឈីម (បានទទួលមរណភាពនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២) ដោយគាត់ត្រូវជាឪពុករបស់ឈ្មោះ [redacted] សុខខេង។ អង្គហេតុមានលក្ខណៈស្របគឺឈ្មោះ [redacted] សុខខេង បានឆ្លើយថា កាលពីឆ្នាំ២០០៧ ខ្លួនបានយកម៉ូតូរបស់ឪពុកខ្លួនឈ្មោះ [redacted] ឈីម ដែលម៉ូតូនោះម៉ាកសង់ការ៉េ យកទៅលក់បានប្រាក់ ៣០០$(បីរយ)ដុល្លាអាមេរិក ហើយប្រាក់នេះយកទៅរៀបចំមង្គលការរបស់ខ្លួន ដែលឪពុកម្តាយរបស់ខ្លួនមិនបានទៅចូលរួមទេ សព្វថ្ងៃពួកគាត់មានកូន០២នាក់ និងកំពុងរស់នៅជុំគ្នា។ ម៉ូតូនេះជាម៉ូតូគាត់ជិះជាប្រចាំដឹកនំបុ័ងឱ្យគ្រួសារខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីបានដកពាក្យ ក្នុងអង្គហេតុនេះថាជាកូនរបស់ខ្លួន ។

អង្គច្បាប់គឺច្បាប់ដែលចោទប្រកាន់ចោទមកលើកូនក្តីរបស់ខ្លួនគឺបទ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ឃើញថា មានប្រតិសកម្មទៅនឹងក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ ដែលបានបញ្ញត្តិថា មាត្រា ៣៥៥ អភ័យឯកសិទ្ធិគ្រួសារ មិនអាចត្រូវផ្តន្ទាទោសទេ អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ ហេតុដូចនេះសូមលោកប្រធានក្រុមប្រឹក្សា និងចៅក្រមប្រឹក្សា ពិចារណាសម្រេចឱ្យកូនក្តីរបស់ខ្លួនបានរួចផុតពីបទចោទប្រកាន់ និងដោះលែងឱ្យមានសេរីភាពឡើងវិញ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចមក

<u>យល់ឃើញថា</u>

-តាមដីកាសន្និដ្ឋានស្តាពររបស់តំណាងអយ្យការ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម បានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] **សុខខេង** ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ពីបទៈ ប្លន់ ប្រព្រឹត្តនៅភូមិទី១៥ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ កាលបើតុលាការផ្ទៀងផ្ទាត់អង្គហេតុដែលជនជាប់ចោទបានប្រព្រឹត្ត តាមអត្តនោម័តគ្មាននូវទុច្ចរិតភាព តុលាការនឹងកំណត់ពិរុទ្ធភាព និងប្រកាសមូលទោសតាមច្បាប់ជាធរមានជាក់ជាមិនខាន ។

-ជនត្រូវចោទជាបុគ្គលមាននីតិភាព និងស្មារតីកាយសម្បទារឹងមាំ ដែលតុលាការអាចកំណត់បាននូវសមត្ថភាពនឹងទទួលខុសត្រូវលើអំពើរបស់ខ្លួនបាន អំពើប្រព្រឹត្តរបស់ជនជាប់ចោទបង្កឡើងធ្វើឱ្យមានការភ្ញាក់ផ្អើល និងប៉ះពាល់ទៅដល់សន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈក្នុងសង្គម ពិសេសនៅចំណុចភូមិទី១៥ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

-តំណាងអយ្យការបានធ្វើសេចក្តីកត់សម្គាល់ដោយរក្សាដីកាសន្និដ្ឋានស្តាពរ របស់តំណាងអយ្យការទុកជាបានការតាមច្បាប់ និងស្នើសុំឲ្យសម្រេចផ្តន្ទាទោសជនជាប់ចោទដោយឆន្ទានុសិទ្ធិ តុលាការកំណត់បានថា តំណាងអយ្យការបានកត់សម្គាល់ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

-លោក [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទបានសន្និដ្ឋានការពារ ស្នើសុំឱ្យតុលាការសម្រេច ឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់ ដោយបញ្ជាក់ថា ជនជាប់ចោទត្រូវជាកូនរបស់ឪពុកឈ្មោះ [redacted] ឈីម និងជាម្ចាស់ម៉ូតូអំពើជនជាប់ចោទស៊ីសង្វាក់មាត្រា ៣៥៣ និងមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការលើកយកមកពិចារណា ។

Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈឹម មិនទាមទារសំណងអ្វីពីជនជាប់ចោទ ខណៈសិទ្ធិវន្តជាប្រពន្ធបានអះអាងឈ្មោះ [redacted] ឈឹម ត្រូវជាប្តីបានស្លាប់ ខ្លួនមិនទាមទារសំណងពីកូនឡើយ ជនជាប់ចោទមានឯកសារភស្តុតាង សៀវភៅស្នាក់នៅ ពិនិត្យជាកូនទី០៣ក្នុងគ្រួសារ តុលាការអត្ថិភាពបានឈ្មោះ [redacted] សុខខេង ពិតជាកូនរបស់ជនរងគ្រោះ តុលាការគប្បីមិនពិចារណានឹងសម្រេច ។

-ជនជាប់ចោទឈ្មោះ [redacted] សុខខេង បានឆ្លើយថា ខ្លួនពិតជាបានយកម៉ូតូរបស់ឪពុកឈ្មោះ [redacted] ឈឹម ម៉ាកសង់ការ៉េពិតមែន ស៊ីសង្វាក់ចម្លើយសារភាពសាក្សីឈ្មោះ [redacted] ឈឿន ជាអ្នកកាន់កាប់ម៉ូតូផ្ទាល់អះអាងថាជាម៉ូតូរបស់ឈ្មោះ [redacted] ឈឹម តុលាការកំណត់បានថា ការយកទ្រព្យសម្បត្តិជាអភ័យឯកសិទ្ធិគ្រួសារ មិនអាចត្រូវផ្តន្ទាទោសទេ អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញ្ញាតិ ឬបច្ឆាញ្ញាតិ អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធឡើយ ហេតុដូច្នេះតុលាការគប្បី ឱ្យឈ្មោះ [redacted] សុខខេង រួចផុតពីបទចោទប្រកាន់ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ ។

-គប្បីកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សុខខេង ពីមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកប្រកាសពិរុទ្ធភាពតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខខេង ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ពីបទ: ប្លន់ ប្រព្រឹត្តនៅភូមិទី១៥ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែគប្បីឱ្យរួចផុតពីបទចោទប្រកាន់ និងសម្រេចឱ្យមានសេរីភាព ។

សាលាដំបូងខេត្តកំពង់ចាម

<u>សិនិច្ឆ័យសេចក្តី</u>

១/ ឱ្យឈ្មោះ [redacted] សុខខេង ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែររួចផុតពីបទចោទប្រកាន់ពីបទ: ប្លន់ ប្រព្រឹត្តនៅភូមិទី១៥ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ ។

២/បង្គាប់ឲ្យដោះលែងឈ្មោះ [redacted] សុខខេង ប្រសិនបើឈ្មោះនេះ មិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

៣/សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខខេង និងឈ្មោះ [redacted] រ៉ាត ជាដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ៦កើត ខែអាសាឍ ឆ្នាំខាល ត្រីស័ក ព.ស២៥៦៦

កំពង់ចាម,ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]